# ហេតុអ្វីត្រូវលះបង់ចោល
# ជំនឿហាឈាហ្វី ?

និពន្ធដោយ សៃឃីដ អ៊ីមដាង់ អ៊ីម៉ាំ

## ហេតុអ្វីត្រូវលះបង់ចោលជំនឿហាណាហ្វី ?

ការយល់ដឹងរបស់ខ្ញុំកើនឡើងរៀងរាល់ថ្ងៃ ការស៊ើបអង្កេតរបស់ខ្ញុំបានឲ្យខ្ញុំដឹងថាសាសនាស្ហ៊ីអ្ហុស្ហ៍ និងសាសនាអាស្ហ៍លុល-ស៊ុនណាស្ហ៍ ជាពិសេសសាសនារបស់អ៊ីម៉ាំ អាប៊ូ ហានីហ្វាស្ហ៍ នោះខុសគ្នាដូចមេឃនិងដី មិនមានចំណុចដូចគ្នាទេរវាងសាសនាទាំងពីរនេះ ឯរឿងជំទាស់នោះក៏ពុំមានអ្វីមួយពាក់ព័ន្ធគ្នាដែរ ។

ម្យ៉ាងទៀត ចំណុចខ្លះស្របច្បាប់ក្នុងសាសនាទាំងពីរ ។ តែការពិតសាសនាស្ហ៊ីអ្ហុស្ហ៍មកពីអល់ឡោះហ្ 1 ឯសាសនាអាស្ហ៍លុល-ស៊ុនណាស្ហ៍ខុសពីសាសនាហាណាហ្វីយ៉ាស្ហ៍ណាស់ ។ ហេតុដូច្នេះ គោលជំនឿនិងច្បាប់របស់សាសនាទាំងនេះពុំមានទំនាក់ទំនងគ្នាទេ ។

មែន ខ្ញុំមិនអាចបង្ហាញចំណុចសំខាន់ៗនិងចំណុចបន្ទាប់បន្សំទាំងអស់បានទេរវាងសាសនាទាំងពីរ តែខ្ញុំអាចសរសេរបានអំពីមូលហេតុដែលខ្ញុំដកខ្លួនចេញពីសាសនាហាណាហ្វី ព្រោះការស៊ើបអង្កេតរបស់ខ្ញុំអំពីសាសនានេះបានឲ្យខ្ញុំដឹងថា អាប៊ូ ហានីហ្វាស្ហ៍ មេដឹកនាំសាសនានេះ បានបង្កើតសាសនានេះឡើងដោយយកតក្កវិជ្ជា (គឺវិជ្ជាត្រិះរិះរកការសមហេតុផលដោយខ្លួនឯង) ជាមូលដ្ឋាន ។ ម៉ៅឡាវី អ្ហុប់ឌុល ការីម ដែលស្លាប់ទៅហើយនោះ ធ្លាប់តែមានប្រសាសន៍ថា អាប៊ូ ហានីហ្វាស្ហ៍ បានផ្តល់គុណប្រយោជន៍ដ៏ធំធេងមួយដល់បណ្តាមុស្លីម ថាលោកបានផ្តល់ឲ្យបណ្តាមុស្លីមនូវសាសនាថ្មីថែសមួយដោយសារលោកប្រើតក្កវិទ្យាសាស្ត្រ ។ មិនមានអ្វីគួរសង្ស័យទេថា អាប៊ូ ហានីហ្វាស្ហ៍ បានក្លាយទៅជាអ្នកប្រឌិតឡើងនូវសាសនាមួយ ការពិត ប្រសិនបើលោកមិនប្រើមធ្យោបាយតក្កសាស្ត្រទេ ប្រាកដជានឹងមិនមានសាសនាថ្មីកើតឡើងទេ ។

## តួយ៉ាងតក្កសាស្ត្ររបស់ អាប៊ូ ហានីហ្វាស្ហ៍ ឬ ហ្វាត់វ៉ារបស់ អាប៊ូ ហានីហ្វាស្ហ៍

តក្កសាស្ត្រ ឬ តក្កវិជ្ជា (គ្ហីយ៉ាស់ قياس ) គឺការត្រិះរិះ ពិចារណារកហេតុផលដោយគំនិតឯង ។

១-គេដឹងច្បាស់ហើយថាយោលតាម អាប៊ូ ហានីហ្វាស្ហ៍ ស្បែកឆ្កែទៅជាបរិសុទ្ធក្រោយពីបានធ្វើឲ្យស្លាប់សាច់ហើយ[1] (គឺសម្លាប់ស្បែកដើម្បីយកមកប្រើការបាន) ។ គេអាចស្ហ៍ឡាត្ហ៍លើស្បែកឆ្កែនោះបាន ។ បើគេចង់ធ្វើក្របគ្ហ៍រអានដោយស្បែកឆ្កែនេះ គេអាចធ្វើបាន ។ នេះសឲ្យឃើញថា អាប៊ូ ហានីហ្វាស្ហ៍ មិនចាត់ទុកសត្វឆ្កែជាសត្វមិនស្អាត មិនបរិសុទ្ធនោះទេ ។

ប្រសើរមែនបើសិនជាស្បែកជ្រូកទៅជាបរិសុទ្ធបានដែរក្រោយពីបានធ្វើឲ្យស្លាប់សាច់ហើយ ។ បើអាចដូច្នេះមែន វាប្រាកដជាមានប្រយោជន៍ណាស់សព្វថ្ងៃនេះ ។ កែបសេះឬអានសេះដែលមានគុណភាពល្អបំផុត គឺកែបដែលធ្វើអំពីស្បែកជ្រូកសុទ្ធតែម្តង ចំណែកឯមុស្លីមសម័យនេះវិញប្រឆាំង

---

[1] សូមមើលសៀវភៅ *ស្ហារហ្ហ៍ អាល់-វ៉ាក្ហ៏យ៉ាស្ហ៍ (شرح الوقاية) ។*

ការប្រើប្រាស់វា ។

២-ស្បែកឆ្កែត្រាំក្នុងវត្ថុកខ្វក់មិនបរិសុទ្ធត្រូវអនុញ្ញាតឲ្យប្រើសម្រាប់ស្វ៏ឡាត្ត៎បាន ដូចលោក ក្វហ្វ៎ហ្វាល់[2] បានស្វ៏ឡាត្ត៎ដោយស្លៀកពាក់ស្បែកបែបនេះជុំជាមួយស្តេចស៊្វលត្ន ម៉ាស៊្ហម្វដ្ហ ក៏ស្ហាន់វី (ابو القاسم محمود غزنوى) ។ រឿងនេះត្រូវបានកត់ត្រាទុកដោយដៃអ៊ីម៉ាំ យ៉ាហ្វ៎អ៊ី (أبي محمد عبد الله بن أسعد اليافعي المكي) នៅក្នុងសៀវភៅ *មីរ៉ាទុល-យ៉ីណាន់ (مرآة الجنان وعبرة اليقظان)* ឯលោក អ៊ីបន្វ ខុល់លីកាន់ (أحمد بن مُحمَّد بن إبراهيم بن أبي بكر بن خلِّكان الشافعي) បានសរសេរអំពីរឿងនេះនៅក្នុងសៀវភៅលោក *វ៉ាហ្វៃវ៉ាទុល-អ៊ុយ៉ាន (وفيات الاعيان وانباء ابناء الزمان)* ដកស្រង់ពីសៀវភៅ *ម្វគីស៊្ហ អាល់-ខុល់ក្វ៏ (مغيث الخلق)* ស្នាដៃរបស់លោក អ៊ីម៉ាមុល-ហ្ហារ៉ម៉ែន៍ (امام الحرمين) និង លោក អាប៊្វ អាល់-ម៉ាអ៊ុលី អាល់-យ្ហ៊ូវ៉ៃនី (ابو المعالي الجويني) ។ យើងត្រូវដឹងថាគេប្រតិបត្តិស្វ៏ឡាត្ត៎នេះយោលតាមការបកស្រាយរបស់សាសនារបស់ អាប៊្វ ហ្ហានីហ្វាស្វ៎ ។ រឿងនេះវែងហួរហែណាស់ ព្រោះវាគួរឲ្យស្អប់ខ្ពើមពេកបានជាលោកអ្នកនិពន្ធមិនសរសេរសាឡើងវិញ ។

ដោយមើលទៅគោលសំខាន់ៗរបស់ស្វ៏ឡាត្ត៎ ។ល ។ យើងបានដឹងថាស្វ៏ឡាត្ត៎បែបនេះព្រមទាំងបំណង (គឺនៀត) និងស្នានពិធី (គឺវ្វឌ្ហ៊្វ៎) នោះជាលទ្ធផលនៃការពឹងផ្អែករបស់អ៊ីម៉ាំទៅលើមតិនិងការត្រិះគិតរបស់ខ្លួនឯងផ្ទាល់ ។

៣-ដោយយោលទៅតាមសៀវភៅ *គីតាប៊ុល-ហ្វ៊ីដ្ហាយ៉ាស្វ៎ (كتاب الهداية)* និងសៀវភៅ *ស្ហារហ្វ៍ វ៉ាក្វ៏យ៉ាស្វ៎ (شرح وقاية)* អាប៊្វ ហ្ហានីហ្វាស្វ៎ អនុញ្ញាតឲ្យផឹកគ្រឿងភេសជ្ជធ្វើអំពីផ្លែលម៉ើត្រាំឲ្យបែកពពុះ និងស្រាដែលធ្វើអំពីផ្លែ ទំពាំងបាយជូរស្ងួត បើអ្នកផឹកមិនស្រវឹងឬពុលទេ ។

ដូចខាងលើនេះដែរ គេបានថ្លែងនៅក្នុង *ហ្វាត់វ៉ា អ៊ុឡាំគីរី (الفتاوى العالمكيرية)* ថាបើអ្នកណាផឹកស្រាផ្លែលម៉ើ ៩ កែវឬពែងហើយមិនស្រវឹងទេ អ្នកនោះមិនត្រូវផ្តន្ទាទោសតាមច្បាប់ទេ ។ អាប៊្វ ហ្ហានីហ្វាស្វ៎ អនុញ្ញាតឲ្យធ្វើស្នានពិធី (គឺយកទឹកវ្វឌ្ហ៊្វ៎) ជាមួយស្រាផ្លែលម៉ើដែរ ។

ជាក់ច្បាស់ណាស់ ការចែងច្បាប់ទាំងអស់នេះរបស់ អាប៊្វ ហ្ហានីហ្វាស្វ៎ ព្រោះតែលោកពឹងពាក់ទៅលើមតិនិងការត្រិះរិះរបស់ខ្លួនលោកផ្ទាល់ ។ ការប្រព្រឹត្តិបែបនេះជាការប្រទូសប្រឆាំងច្បាប់គួរអាន ។ ដោយហេតុតែ អាប៊្វ ហ្ហានីហ្វាស្វ៎ អនុវត្តិតាមមតិខ្លួនឯងបែបនេះ បានជាអ្នកប្រតិបត្តិតាមនិកាយលោកមួយចំនួននោះគិតថាគេអនុញ្ញាតឲ្យផឹកស្រាធ្វើអំពីផ្លែឈើតូចៗ (ផ្លែបេរី berry) ។

៤-ដោយយោលទៅលើកំណត់ហេតុនៅលើរឹមសៀវភៅ *ស្ហារហ្វ៍ វ៉ាក្វ៏យ៉ាស្វ៎ (شرح وقاية)* អាប៊្វ ហ្ហានីហ្វាស្វ៎ យល់ឃើញថាការបង់ប្រាក់ឲ្យទៅស្រីពេស្យានោះជាការស្របច្បាប់សម្រាប់ស្រីពេស្យានោះ ។

---

[2] ក្វហ្វ៎ហ្វាល់ (أبو بكر القفال الشاشي) អ្នកច្បាប់ស្ហាហ្វ៊ីអ៊ីដំបូងបង្អស់ដែលគេចាត់ទុកជាអ្នកផ្សាយសាសនាស្ហាហ្វ៊ីអ៊ីនៅឯតំបន់អាស៊ីកណ្តាល (ឬ Transoxania) លុបលើសាសនាហ្ហាន់បាលី ។

ដូចខាងលើនេះដែរ គេបានបង្ហាញភ័ស្តុតាងដកស្រង់ពី *ហ្វាត់វ៉ា ក៏្ឌី ខាន (فتاوى قاضي خان)* និង *កាន់ស៊ុល-ដ្ឋាក៏្អ៊ីក្វ (كنز الدقائق)* ថាបុរសណាចំណាយប្រាក់ទៅលើអំពើទាក់ទងនឹងផ្លូវភេទ (ពោលគឺរួមភេទខុសច្បាប់) បុរសនោះមិនប្រឈមនឹងទណ្ឌកម្មទេ ។

ប្រសិនបើការអនុម័តច្បាប់បែនេះរបស់ អាប៊ូ ហ្កានីហាស៊ូ ត្រឹមត្រូវមែននោះ ប្រាកដជាស្រីពេស្យាទាំងអស់នៅក្នុងផ្សារមិនមានកំហុសទេ ។ ប្រសិនបើទំនាក់ទំនងនេះសមស្របតាមច្បាប់មែននោះ ហេតុអ្វី មុតអាុស៊ូ មិនសមស្របតាមច្បាប់ ទោះបីត្រូវគួរអានអនុម័តក៏ដោយ ?

៥-យោលតាម អាប៊ូ ហ្កានីហ្វាស៊ូ កាន់សាច់សត្វដែលច្បាប់អនុញ្ញាត (គឺសាច់ហ្កាឡាល់) នៅក្នុងសាច់ជ្រូកស្តើងមួយបន្ទះជាទង្វើស្របច្បាប់ ។ យោលតាម អាប៊ូ ហ្កានីហ្វាស៊ូ ព្រោះតែជ្រូកមិនមែនសត្វដែលមិនបរិសុទ្ធដូចឆ្កែទេនោះ កែបសេះដែលធ្វើអំពីស្បែកជ្រូកក៏មិនអាចមិនស្របច្បាប់ទេដែរ ។ ផ្ទុយទៅវិញ តក្កសាស្ត្រ (គឺវិជ្ជាត្រិះរិះ) ទាមទារថា ពេលគេអាចប្រើបន្ទះស្តើងនៃសាច់ជ្រូកបាននោះ ការចៀសវាងប្រើស្បែកជ្រូកនោះពុំមានន័យទេ ។

៦-គេបានថ្លែងនៅក្នុង *ហ្វាត់វ៉ា ក៏្ឌី ខាន (فتاوى قاضي خان)* ថាសរសេរគួរអានជាមួយទឹកនោម ជាមួយឈាម ឬ វត្ថុកខ្វក់នានានោះជាការស្របច្បាប់ ពីព្រោះគេប្រើវត្ថុទាំងនេះដើម្បីបន្សាបរោគ ។

ពិតប្រាកដណាស់ នេះគឺការបង្ហាញឲ្យឃើញនូវការប្រមាថមើលងាយធ្ងន់ទៅលើព្រះមហាគម្ពីរគួរអាន ។

៧-ដោយយោលទៅលើសៀវភៅ *ហ៊ីដ្ឋាយ៉ាស៊ូ*[3] បើបុរសណារៀបការជាមួយបងប្អូនស្រីរបស់ម្តាយ កូនស្រី ឬ អ្នកសាច់សាលោហិតជិតដោយចេតនានិងដោយប្រើកម្លាំងបង្ខំ បុរសនោះមិនអាចត្រូវពិន័យបានទេ ។ ច្បាស់ណាស់ ការអនុម័តច្បាប់នេះស្រដៀងនឹងទំនៀមទម្លាប់របស់ពួកម៉ាយ៉ូស (គឺពួកគោរពសក្ការៈភ្លើង) មិនមានជាប់ពាក់ព័ន្ធជាមួយច្បាប់អ៊ីស្លាមទេ ។

៨-យោលតាម *ហ្វាត់វ៉ា អាុឡាំគីរី (الفتاوى العالمكيرية)* និង *អាល់-ឌូរ អាល់-មុក្តារ (الدر المختار)* បើបុរសណាអះអាងដោយកុហកថាស្ត្រីណាមួយជាភរិយាស្របច្បាប់របស់ខ្លួន ដោយមានសាក្សីកុហក ហើយបុរសនោះឈ្នះក្តីដោយស្របនឹងការសម្រេចក្តីរបស់ចៅក្រម (ក៏្ឌី) អ៊ីស្លាម បុរសនោះបានស្ត្រីនោះ ស្ត្រីនោះទៅជាស្ត្រីស្របច្បាប់សម្រាប់បុរសនោះ ចំពោះអល់ឡោះហ៊ូ عزوجل និងចំពោះមនុស្ស ហើយបុរសនោះមិនត្រូវទទួលទោសណាមួយទេ ។
ដោយយកតាមរបៀបនេះដែរ ទ្រព្យទាំងអស់ ប្រាសាទ លំនៅដ្ឋាន ។ល។ ទៅជាសមស្របតាមច្បាប់អាស្រ័យលើសាក្សីបំភាន់ ។ ការអនុម័តច្បាប់នេះចម្លែកមែន ! ពិតប្រាកដណាស់ នីតិសាស្ត្រ

[3] ទំព័រ ៤៩៦ ។

(ហ្វ៊ីក្មេះត្ត៍) បែបនេះហាក់ដូចជាប្រភពនៃការផ្សាយឲ្យប្រព្រឹត្តការថ្លែងបំភាន់ ។

បែបអនុម័តច្បាប់ទាំងអស់នេះជាលទ្ធផលនៃតក្កសាស្ត្រ និងជាការឆ្លុះបញ្ចាំងអំពីសមត្ថភាពចែងច្បាប់គួរឲ្យឡប់ស្មារតីរបស់ អាប៊ូ ហ្ហានីហ្វាស់ ។

អ្នកនិពន្ធរមែងតែភ្ញាក់ផ្អើល ក្នុងអំឡុងពេលដែលខ្លួនមិនដឹងអ្វីនោះ ថាហេតុអ្វីបានជាពួកវ៉ាស់ហ្វាប៊ី និងពួកអ្នកតាមសាសនាហ្ហាណាហ្វ៊ីនោះស្អប់គ្នាណាស់ ។ ព័ត៌មានក្រោយៗមកបានបង្ហាញឲ្យឃើញថាអំណះអំណាងរបស់ពួកវ៉ាហ្វាប៊ីផ្អែកទៅលើគម្ពីរអាននិងហ្ហាឌីស្ហ ចំណែកឯពួកហ្ហាណាហ្វ៊ីវិញផ្អែកទៅលើមតិខ្លួនឯងនិងតក្កវិជ្ជាទាំងស្រុង ។

មែន ពេលនិកាយណាមួយឲ្យតម្លៃខ្លាំងពេកទៅលើមតិខ្លួនឯងនិងតក្កសាស្ត្រ តើនិកាយនោះអាចមានទំនាក់ទំនងយ៉ាងណាជាមួយនិកាយមួយទៀត ដែលផ្អែកទៅលើគម្ពីរអាននិងហ្ហាឌីស្ហតែមួយមុខ ? ហេតុដូច្នេះ មិនមានអ្វីគួរឲ្យសង្ស័យទេដែលពួកវ៉ាស់ហ្វាប៊ីឯាកចេញពីពួកកាន់សាសនាហ្ហាណាហ្វ៊ីនោះ ។ ចំណែកឯសាសនាស្ហាហ្វ៊ីអ៊ីវិញមិនដូចនេះទេ ព្រោះអ៊ីម៉ាំស្ហាហ្វ៊ីអ៊ីមិនផ្អែកលើមតិខ្លួនឯងនិងតក្កសាស្ត្រទេ ខុសពី អាប៊ូ ហ្ហានីហ្វាស់ ។

សម្រាប់អ្នកនិពន្ធ សាសនាវ៉ាស់ហ្វាប៊ីមានលក្ខណៈជាសាសនាអ៊ីស្លាមជាងសាសនាហ្ហាណាហ្វ៊ី រីឯជំនឿហ្ហាណាហ្វ៊ីវិញហាក់ដូចជាស្ថិតនៅលើព្រឹត្តិការណ៍ថ្មីចំនួនពីរភាគបី មិនទាក់ទងនឹងសាសនារបស់ព្រះសាស្តា មូហ៊ាំម៉ាដ់ មុស្ហត្ត៍ហ្វា ﷺ ទេ ។

សូមស្លេះសាច់រឿងត្រឹមនេះ គួយ៉ាងទាំងនេះគ្រប់គ្រាន់ណាស់ហើយ ។ យើងត្រូវដឹងថាដោយសារតែ អាប៊ូ ហ្ហានីហ្វាស់ អនុវត្តិការអារកាត់ដោយខ្លួនឯងនិងតក្កសាស្ត្រ បានជានិកាយរបស់លោកមានលក្ខណៈប្លែកនិងហាក់ដូចជាមានកម្រិតខ្ពស់ជាងនិកាយស្ហ៊ីអ៊ាស់ និកាយស្ហាហ្វ៊ីអ៊ី និកាយហ្ហាន់បាលី និងនិកាយម៉ាលីគី ។ នេះគឺការឆ្មៃប្រឌិតរបស់និកាយនេះ ដល់ថ្នាក់សូម្បីតែសិស្សពីរនាក់របស់ អាប៊ូ ហ្វានីហ្វាស់ គឺ អាប៊ូ យូស៊ុហ្វ និង អ៊ីម៉ាំ មូហ៊ាំម៉ាដ់ ក៏បោះបង់ចោលនូវអធិបតីភាពរបស់ អាប៊ូ ហ្ហានីហ្វាស់ ដែរទាក់ទងនឹងរឿងសំខាន់ៗប្រមាណពីរភាគបី ហើយយោលតាមលោកក៏ស្ហាលី ដែលមានប្រសាសន៍នៅក្នុងសៀវភៅលោក *អាល់-ម៉ានឃូល (المنخول)* ថា៖ "អាប៊ូ ហ្ហានីហ្វាស់ បានបោចឫសជំនឿអ៊ីស្លាមចោល ហើយបានបង្កើតនិកាយរបស់ខ្លួនឯង ។"

សូមយកតែប៉ុណ្ណេះ ទោះបីនៅមានព័ត៌មានច្រើនទៀតពាក់ព័ន្ធនឹងសាច់រឿងនេះដែលអាចចងក្រងឡើងបានជាសៀវភៅក្បោះក្បាយមួយក៏ដោយ ។ យោលតាមសៀវភៅច្រើនទៀត អាប៊ូ ហ្ហានីហ្វាស់ ផ្អែកទៅលើតក្កសាស្ត្រយ៉ាងច្រើន ព្រោះលោកចេះដឹងហ្ហាឌីស្ហតិចណាស់ ដូចលោកក៏ស្ហាលី បានមានប្រសាសន៍នោះជាដើម ។ លោក ក៏ស្ហាលី មានប្រសាសន៍ដែរថា អាប៊ូ

ហ៊ានីហ្វាស្ទ មិនចេះដឹងច្បាប់អ៊ីស្លាមយ៉ាងត្រឹមត្រូវទេ ។ តទៅនេះ សូមផ្តល់ព័ត៌មានអំពីជំនឿនិងនីតិសាស្ត្រ របស់ អាប៊ូ ហ៊ានីហ្វាស្ទ ។

## ជំនឿនិងហ្វីក្ហោះហ្វ៍ (នីតិសាស្ត្រ) របស់ អាប៊ូ ហ៊ានីហ្វាស្ទ

មុននឹងសរសេរឲ្យបានក្បោះក្បាយអំពីលោក គប្បីពិនិត្យសម្តីរបស់សិស្សខ្លះរបស់លោកដែលកាន់ជើងលោកអំពីរឿងដែលលោកមិនបានសរសេរសៀវភៅណាមួយទេស្តីអំពីហ្វីក្ហោះហ្វ៍ (គឺច្បាប់សាសនា) នោះ ថាបើលោកបានសរសេរសៀវភៅ បានលើកឡើងនូវរឿងនេះមែន លោកនឹងត្រូវថ្កោលទោស តែព្រោះតែលោកមិនបានសរសេរអ្វីទេ មិនបានផលិតសៀវភៅបែបនេះណាមួយទេនោះ លោករួចខ្លួនពីការចោទប្រកាន់និងការថ្កោលទោសទាំងអស់ ។

ចម្លើយគឺ ដោយយោលទៅលើសម្តីនេះ អ៊ីម៉ាម៉ាត់របស់ អាប៊ូ ហ៊ានីហ្វាស្ទ ត្រូវរលាយសូន្យបង់តែម្តង ។ បានសេចក្តីថា ព្រោះតែពុំមានឯកសារណាមួយសោះសរសេរដោយដៃលោកដែលស្តីអំពីបញ្ហាដែលធ្វើឲ្យមានជម្លោះណាមួយនោះ ហ្វីកោះហ្វ៍ (គឺកម្រងច្បាប់ផ្នែកសាសនា) របស់លោកពុំមានតម្លៃឡើយ ។

ហេតុដូច្នេះ អ្វីៗដែលបានចារទុកអំពីសាសនាហ៊ាណាហ្វីដែលគេកំពុងតែប្រើសព្វថ្ងៃនេះត្រូវគេចាត់ទុកថាជាស្នាដៃរបស់ អាប៊ូ ហ៊ានីហ្វាស្ទ ។ ព្រោះតែខ្លួនលោកផ្ទាល់មិនបានសរសេរសៀវភៅណាមួយសោះពាក់ព័ន្ធនឹងវិស័យចំណេះដឹងនោះ តើគេអាចនិយាយបានដូចម្តេចថាហ្វាត់វ៉ាទាំងអស់ជារបស់លោក ? អាស្រ័យលើករណីនេះ សាសនាទាំងមូលរបស់ អាប៊ូ ហ៊ានីហ្វាស្ទ រលាយសូន្យតែម្តង ។

សៀវភៅសាសនាហ៊ាណាហ្វីទាំងអស់ ដូចជា ហ៊ីដ្ដាយ៉ាស្ទ (هداية), ស្ហារហ៍ វ៉ាគ្វ៉ីយ៉ាស្ទ (شرح وقاية), ហ្វាត់វ៉ា ក៏ដ្ឋី ខាន (فتاوى قاضي خان), ហ្វាត់វ៉ា អាឡាំគីរី (الفتاوى العالمكيرية) ជាដើមនោះត្រូវបានសរសេរឡើងដោយឥតប្រយោជន៍ ។ ការពិតគឺអ៊ីមុាំមូហ៊ាំម៉ាដ្ទ, អ៊ីមុាំអាប៊ូ យូស៊ុហ្វនិងព្រឹទ្ធាចារ្យទាំងអស់របស់អស់លោកនេះធ្លាក់ទៅក្នុងស្ថានភាពគ្រោះថ្នាក់ធំ ។ និយាយឲ្យខ្លី ជាមួយនឹងការលើកចោលសាសនាហ៊ាណាហ្វីនេះ អ៊ីម៉ាម៉ាត្ទរបស់ អាប៊ូ ហ៊ានីហ្វាស្ទ និងភាពជាសន្តបុគ្គលរបស់លោកក៏ត្រូវរលាយអស់ដែរ ។ ភ័ក្តីភាពចំពោះអ៊ីមុាំនេះអស្ចារ្យមែន ! ព្រោះតែប្រឹងប្រែងជួយស្រង់លោកពីការស្តីបន្ទោសមុនៗនោះ ពួកគាត់បានកម្ទេចចោលទាំងភ្លីភ្លើនូវភាពជាសន្តបុគ្គលរបស់អ៊ីមុាំ ។

អាប៊ូ ហ៊ានីហ្វាស្ទបានកើតក្នុងឆ្នាំ ៨០ នៃសករាជអ៊ីស្លាម ឬពីរឬបីឆ្នាំមុន ដែលជាឆ្នាំប្រសូតអ៊ីមុាំ យ៉ាក្ហ៊ូហ្វារ ស្វ៉ាឌិក្វ صلوات الله عليه والسلام ដែរ ។ លោកបានទទួលអនិច្ចកម្មពីរឬបីឆ្នាំបន្ទាប់ពីអ៊ីមុាំ យ៉ាក្ហ៊ូហ្វារ ស្វ៉ាឌិក្វ صلوات الله عليه والسلام បានចូលទិវង្គត ។ ហេតុដូច្នេះ លោកជាបុគ្គលស្រករព្រះសន្តអ៊ីមុាំ صلوات الله عليه والسلام ដែរ ។ លោកធ្លាប់តែទៅជួបអ៊ីមុាំ យ៉ាក្ហ៊ូហ្វារ ស្វ៉ាឌិក្វ صلوات الله عليه والسلام ជាធម្មតាដោយមិនយល់ស្របតាមព្រះអង្គ صلوات الله عليه والسلام រឿងណាមួយ

ឡើយ ។ តែព្រោះតែលោកមានឋានៈជាអ្នកប្រឆាំង ជូនកាលលោកបានផ្ចាញ់ផ្ចាលអ៊ីម៉ាំ យ៉ាក់ហ្វារ ស្វ៉ាឌិក្វ صلوات الله عليه والسلام ទៀតផង ឯអ៊ីម៉ាំយ៉ាក់ហ្វារ ស្វ៉ាឌិក្វ صلوات الله عليه والسلام ក៏មិនបិទបាំងរឿងនេះដែរ ។ ជាការយល់ខុសដែលថា អាប៊ូ ហ៊ានីហ្វាស់ បានទទួលកិត្តិយសជាសិស្សរបស់អ៊ីម៉ាំ យ៉ាក់ហ្វារ ស្វ៉ាឌិក្វ صلوات الله عليه والسلام នោះ ។

ការស្រាវជ្រាវបានឲ្យដឹងថា អាប៊ូ ហ៊ានីហ្វាស់ មិនដែលស្រឡាញ់អ៊ីម៉ាំ យ៉ាក់ហ្វារ ស្វ៉ាឌិក្វ صلوات الله عليه والسلام ទេ មិនដែលគិតថាការស្រឡាញ់របស់លោកនេះ នឹងប្រកបដោយមគ្គផលជួយខ្លួនលោកឲ្យរួចផុតពីមហាទុក្ខទេ ។ ផលប្រយោជន៍ធំសម្រាប់ អាប៊ូ ហ៊ានីហ្វាស់ គឺលោកត្រូវតែបន្តការប្រទូសប្រឆាំងអ៊ីម៉ាំសម័យកាល លោកប្រើការប្រឆាំងនេះជាឧបករណ៍ប្រមូលប្រជាប្រិយភាពល្បីល្បាញ ។ សំណាងល្អ ឱកាសល្អបានហុចឲ្យ អាប៊ូ ហ៊ានីហ្វាស់ ប្រកួតប្រជែងអ៊ីម៉ាំសម័យកាល ។ នេះព្រោះតែស្តេច ខ៉ំលិហ្វ ម៉ាន់ស៊្វរ សម្បូរដោយអមិត្តភាពមកលើ អ៊ីម៉ាំ យ៉ាក់ហ្វារ ស្វ៉ាឌិក្វ صلوات الله عليه والسلام ជាសត្រូវស្លាប់រស់របស់អ៊ីម៉ាំ صلوات الله عليه والسلام ។

ទីបំផុត ស្តេចនេះបានដាក់ថ្នាំបំពុលសម្លាប់អ៊ីម៉ាំ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ចាកលោកនេះទៅកាន់ព្រះសុគតិភព ។ ស្តេចខ៉ំលិហ្វម៉ាន់ស៊្វមិនចង់ឲ្យប្រជារាស្ត្រប្រតិបត្តិតាមនីតិសាស្ត្រ (ហ្វីកោះហ្វ៍ គឺច្បាប់សាសនា) របស់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ទេ នេះគឺមូលហេតុដែលក្សត្ររូបនេះតែងតែចូលរួមក្នុងការធ្វើឲ្យនីតិសាស្ត្ររបស់ អាប៊ូ ហ៊ានីហ្វាស់ មាននូវប្រជាប្រិយភាពល្បីល្បាញ ។ ទំនៀមទម្លាប់មួយរបស់ស្តេចខ៉ំលិហ្វគ្មានសាសនារូបនេះគឺ ស្តេចក្រៅធម្មរូបនេះតែងតែផាកមួយកាក់មាសបុគ្គលណាដែលសួរដល់ច្បាប់សាសនាអ៊ីស្លាមអនុម័តដោយអ៊ីម៉ាំ យ៉ាក់ហ្វារ ស្វ៉ាឌិក្វ صلوات الله عليه والسلام ឲ្យរង្វាន់មួយកាក់មាសដល់បុគ្គលណាដែលសាកសួរអំពីច្បាប់សាសនាអ៊ីស្លាមអនុម័តដោយ អាប៊ូ ហ៊ានីហ្វាស់ ។

ជាក់ស្តែងណាស់ សាសនារបស់ អាប៊ូ ហ៊ានីហ្វាស់ បានជឿនលឿនទៅមុខយ៉ាងខ្លាំងអាស្រ័យការឧបត្ថម្ភរបស់ស្តេចខ៉ំលិហ្វ ។ ដូច្នេះ ហេតុអ្វីលោកបណ្តោយឱកាសល្អ ដែលមានតែមួយដងក្នុងមួយជីវិតនោះកន្លងហួសទៅបាត់ ? ដូច្នេះ ដែលលោកតែងតែប្រឆាំងអ៊ីម៉ាំ صلوات الله عليه والسلام នោះមិនមែនអ្វីដែលមិនបានស្មានទុកជាមុននោះទេ ។ ការពិតនោះគឺ អាប៊ូ ហ៊ានីហ្វាស់ មិនបាននូវផលប្រយោជន៍ណាមួយទេពីការតាមអ៊ីម៉ាំត្រឹមត្រូវ صلوات الله عليه والسلام នោះ ជាពិសេសពេលស្តេចខ៉ំលិហ្វសម័យនោះជាសត្រូវរបស់អ៊ីម៉ាំ صلوات الله عليه والسلام ។ អាប៊ូ ហ៊ានីហ្វាស់ ជាអំណោយដែលស្មានមិនដល់សម្រាប់ស្តេចម៉ាន់ស៊្វរ ។ ឯរូបអាប៊ូ ហ៊ានីហ្វាស់ ក្នុងនាមជាអ្នកប្រឆាំងអ៊ីម៉ាំ صلوات الله عليه والسلام ក៏តែងតែផ្គាប់ផ្គុនស្តេចខ៉ំលិហ្វដែរ ។

សេចក្តីរាយការណ៍លំអិតអំពីទំនាក់ទំនងរបស់ អាប៊ូ ហ៊ានីហ្វាស់ ជាមួយរាជវាំងម៉ាន់ស៊្វរនោះគឺកាលលោកបានចូលមក ស្តេចខ៉ំលិហ្វបានសួរលោកថាលោកបានការចេះដឹងមកពីណា ។ អាប៊ូ ហ៊ានីហ្វាស់ បានឆ្លើយថា៖ "បានមកពី អ៊ុម៉ារ ប៊ិន ខុត្តត្តប់, បានមកពី អាលី ប៊ិន អាប៊ី ត៉លិប صلوات الله عليه والسلام និង អាប់ឌុលឡោះហ្វ៍ ប៊ិន អាប់បាស់ និងបានមកពីអ្នករាយការណ៍ពីអស់លោកនេះ ។ ចុងក្រោយលោកបានថាក្នុងរជ្ជកាល អ៊ីបនូ អាប់បាស់ ពុំមានអ្នកណាដូចស្តេចនេះទេ (គឺដូចម៉ាន់ស៊្វរ) ។" ព្រោះតែជាត្រកូល អ៊ីបនូ អាប់បាស់ ដែរបានស្តេចម៉ាន់ស៊្វរត្រូវចិត្តនឹងឃ្លាចុងក្រោយនេះ ។ ចាប់តាំងពីថ្ងៃនោះតរៀងមក បុគ្គលទាំងពីរនេះស្និទ្ធស្នាលគ្នាណាស់ សាសនារបស់ អាប៊ូ ហ៊ានីហ្វាស់

ក៏បានលេចប្រចក្សឡើង ។

រឿងនេះសឲ្យឃើញថាអាប៊ូ ហ្កានីហ្វាស្ទ់ជាមនុស្សឆ្លាតណាស់ តើមានអ្វីខុសក្នុងសេចក្ដីរាយការណ៍របស់លោកអំពី អុាប់ឌុលឡោះហ្វ៍ ប៊ិន អុាប់បាស់នោះ ? ដើម្បីយកស្ដេចខ៉ិលិហ្វជាសិស្សរបស់លោកក្នុងការសាកល្បងដំបូងនោះ លោកប្រាប់អំពីគតិប្រាជ្ញារបស់លោក ។ មិនគួរឲ្យសង្ស័យទេ លោកជាមនុស្សថ្វីគំនិតណាស់ ។ លោកបានថា ដំបូងលោកចង់ចេះដឹងគួរអាននិងចង់ចងចាំគួរអានរត់មាត់ តែហាក់ដូចជាមិនបានទទួលផលប្រយោជន៍ទេ ដូច្នេះលោកបានសម្រេចចិត្តសិក្សាហ្កាឌីស្ទ្រ តែនេះក៏ហាក់ដូចជាឥតប្រយោជន៍ដែរ ។ ក្រោយពីនោះ លោកបានសម្រេចចិត្តទៅជាអ្នកវេយ្យាករណ៍ តែលោកមិនអាចអត់ទ្រាំជាគ្រូបង្រៀនបានទេ ។

ក្រោយមក លោកបានសម្រេចចិត្តទៅជាកវី តែមុខរបរនេះក៏មិនមានកម្រៃដែរ ។ ទីបំផុត លោកចង់ទៅជាអ្នកឯកទេសខាងច្បាប់អ៊ីស្លាមវិញ ពីព្រោះអាស្រ័យមុខរបរនេះគេអាចទទួលបាននូវឋានៈខ្ពស់ជាងគេក្នុងលោក ហើយគេអាចបានក្លាយទៅជាក្ហ៍ឌី (គឺចៅក្រម ឬ ចៅអធិការ قاضي) ។ អ្នកធំៗនិងស្ដេចនានាពឹងផ្អែកលើក្ហ៍ឌី ។ សម្ដីនេះសឲ្យឃើញថា អាប៊ូ ហ្កានីហ្វាស្ទ់ ជាបុរសប្រាជ្ញាមុត ។ លោករើសសម្រិតសម្រាំងយកមុខរបរណា ដែលផ្ដល់ឲ្យនូវផលប្រយោជន៍ច្រើនបំផុតសម្រាប់លោក មុខរបរនោះមានផលប្រយោជន៍ណាស់ក្នុងរជ្ជកាលស្ដេចខ៉ិលិហ្វអារ៉ាប់ ដូចមុខរបរមេធាវីក្នុងសម័យនេះដែរ ។ គេអាចក្លាយទៅអ្នកមានធំអាស្រ័យមុខរបរនេះ ។

ដូច្នេះ អាប៊ូ ហ្កានីហ្វាស្ទ់ បានជ្រើសយកមុខរបរអ្នកធម្មសាស្ត្រអ៊ីស្លាម (ហ្វាគ្ហិះហ្វ៍ فقه) ហើយបានទទួលជោគជ័យកំពូល ។ លោកមានថ្វីគំនិតខ្ពស់ដ្បិតលោកមិនបានយកតាមធម្មប្បដិបត្តិ (ហ្វីក្ហោះហ្វ៍) របស់អ៊ីម៉ាំ យ៉ាក្កហ្វារ ស្វ៍ឌិក្គ صلوات الله عليه والسلام ទេ ។ បើសិនជាលោកលំអៀងទៅរកធម្មប្បដិបត្តិរបស់អ៊ីម៉ាំ صلوات الله عليه والسلام ទោះបីបន្តិចបន្តួចក៏ដោយ លោកនឹងពុំល្បីល្បាញ ពុំមានជោគជ័យ ពុំមានអំណាច ពុំមានកេរ្ដិ៍ឈ្មោះ ដូចលោកដែលទទួលបានព្រោះតែលោកប្រឆាំងអ៊ីម៉ាំ صلوات الله عليه والسلام នោះទេ ។

ការពិតគឺ អាប៊ូ ហ្កានីហ្វាស្ទ់ ជាបុរសឆ្លៀតប្រយោជន៍ក្នុងសម័យលោក ។ ហេតុអ្វីលោកគប្បីធ្វើតាមការដាស់តឿនរបស់មនុស្សភ្លីភ្លើ ព្រមទៅជាសិស្សរបស់អ៊ីម៉ាំ យ៉ាក្កហ្វារ ស្វ៍ឌិក្គ صلوات الله عليه والسلام ? ហេតុអ្វីលោក គប្បីតាមព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ? បើលោកបានធ្វើបែបនេះមែនប្រាកដជានឹងមានការប្រកែកគ្នារវាង ខ៉ិលិហ្វម៉ាន់ស្ទ្វរ និង អាប៊ូ ហ្កានីហ្វាស្ទ់ ហើយលោកនឹងត្រូវស្ដេចរូបនេះដាក់ទោស ។ លោកមិនមាន ទឹកចិត្តគាំទ្រ អ៊ីម៉ាំ យ៉ាក្កហ្វារ ស្វ៍ឌិកគ្គ صلوات الله عليه والسلام ទេ ដោយសារមុខរបរលោក ។ បើលោកមានទឹកចិត្ត គាំទ្រអ៊ីម៉ាំ យ៉ាក្កហ្វារ ស្វ៍ឌិក្គ صلوات الله عليه والسلام មែននោះលោកច្បាស់ជាមិនបាននិយាយដោយចំអកដាក់លោក មុមីន អាល់-ត្ហក្ហ់[4] ទេថា៖ "អ៊ីម៉ាំ صلوات الله عليه والسلام របស់លោកស្លាប់ហើយ !" លោក មុមីន អាល់-ត្ហក្ហ់ បានតបវិញ ថា៖

[4] មុមីន អាល់-ត្ហក្ហ់ (مؤمن الطاق) នាមពិតរបស់លោកគឺ អាប៊ូ យ៉ាក្កហ្វារ មូហ្កាំម៉ាដ្ទ ប៊ិន អុាលី ប៊ិន នុអ៊្ម៉ាន អ៊ីបនូអាប៊ី ទ្ហ៉យ៉ហ្វាស្ទ់ អាល់-បាយ៉ាលី អាល់-គូហ្វី (ابو جعفر محمّد بن علي بن نعمان ابن أبي طريفة البجلي الكوفي) ជាសាវ័ករបស់អ៊ីម៉ាំ យ៉ាក្កហ្វារ អាល់-ស្វ៍ឌិក្គ صلوات الله عليه والسلام ។

"ការពិតអ៊ីម៉ាំរបស់លោកបានទទួលការពន្យារពេលលុះដល់ថ្ងៃជំនំជម្រះ ។" មិនចាំបាច់បកស្រាយអត្ថន័យរបស់ពាក្យ "អ៊ីម៉ាំ" ដែលលោក មុមីន អាល់-តក្ក៌ បាននិយាយដល់នោះទេ គ្រាន់តែថាដូចតទៅនេះវាគ្រប់គ្រាន់ណាស់ហើយគឺៈ "ឡា ហៅឡា វ៉ា ឡា គូវ៉ាតា អ៊ិលឡា ប៊ិលឡាស់ ... (ការមានឥទ្ធិឫទ្ធិនិងកម្លាំងអាស្រ័យតែលើអល់ឡោះហ្ عز وجل ... لَا حَوْلَ وَلَا قُوَّةَ إِلَّا بِٱللَّهِ)

ក្រៅពីនេះ អាប៊ូ ហ៊ានីហ្វាស់ ក៏មិនមានសមានចិត្តចំពោះអ៊ីម៉ាំ អ៊ាលី មួរតាដ្ឋ៏ صلوات الله عليه والسلام ទេដែរ ។ យោលតាមសេចក្តីរាយការណ៍របស់លោក មូហ៊ាំម៉ាដ្ជ ណៅហ្វាល់ ដែលបានឲ្យដឹងថាៈ "គ្នាយើងច្រើននាក់បានអង្គុយនិយាយគ្នា លុះ អាប៊ូ ហ៊ានីហ្វាស់ មកដល់ ។" គេកំពុងនិយាយគ្នាអំពីរឿងម្ចាស់អ៊ាលី صلوات الله عليه والسلام ។ អាប៊ូ ហ៊ានីហ្វាស់ បានថាៈ "គេមិនត្រូវនិយាយអំពីហ៊ាឌីស្ស ក៏ុដៀរ ទេ ។ ខ្ញុំបានហាមអ្នកតាមខ្ញុំចំពោះរឿងនេះ ។"

លោក ហ្វាស៊ីម ប៊ិន ហ៊ាប៊ីប សៃរ៉ហ្វី បានក្រោធហើយថាៈ "លោកដឹងទេថាម្ចាស់ អ៊ាលី صلوات الله عليه والسلام បានប្រាប់បណ្តាសាវកព្រះអង្គ صلوات الله عليه والسلام ឲ្យទទួលយកហ៊ាឌីសនេះព្រោះនេះជាហ៊ាឌីស្សពិត ?" អាប៊ូ ហ៊ានីហ្វាស់ ថាៈ "មានការសង្ស័យ មិនច្បាស់ថាសេចក្តីរាយការណ៍ហ៊ាឌីស្សនេះពិតឬទេ ។ ពួកស៊្ហីអ៊ាស់គិតខ្លាំងណាស់អំពីរឿងនេះ ហើយបៀតបៀនពួកមិនមែនស៊្ហីអ៊ាស់ ។"

នេះសឲ្យឃើញថា អាប៊ូ ហ៊ានីហ្វាស់ មិនមានទឹកចិត្តអាណិតគាំទ្រម្ចាស់អ៊ាលី صلوات الله عليه والسلام ទេ ។ គួរឲ្យឆ្ងល់ណាស់ថាហេតុអ្វី អាប៊ូ ហ៊ានីហ្វាស់ មិនអនុញ្ញាតឲ្យបណ្តាអ្នកតាមលោកនោះទទួលយកហ៊ាឌីស្សដែលអ៊ាលី صلوات الله عليه والسلام បានប្រាប់ឲ្យបណ្តាសាវកព្រះអង្គ صلوات الله عليه والسلام ទទួលយកព្រោះវាជាហ៊ាឌីស្សពិត ហើយណាប៊ី صلى الله عليه وآله وسلم ក៏បានប្រកាសក្តែងៗហ៊ាឌីស្សនេះពីលើវេទិកាដែរ ! ទោះបីលោកជាអ្នកប្រឆាំងអ៊ីម៉ាំយ៉ាក់ហ្វារ ស្ហ៏ឌិក្ក صلوات الله عليه والسلام និងអ៊ីម៉ាំ អ៊ាលី មួរតាដ្ឋ៏ صلوات الله عليه والسلام ក៏ដោយ បណ្តាអ្នកតាម អាប៊ូ ហ៊ានីហ្វាស់ ប្រកាសជំទាស់ថាលោកស្មោះភ័ក្តីចំពោះ អាស្ហ៍លុល-បៃត៍ عليهم السلام !

សូមលើកយកចំណុចមួយទៀតទាក់ទងនឹង អាប៊ូ ហ៊ានីហ្វាស់ ដែលខ្ញុំបានដឹងមកពីការស្រាវជ្រាវ ។ លោក អ៊ាប់ឌុល ក៏ាដៀរ យ៉ីឡានី (عبد القادر الجيلاني) ដែលជាសន្តបុគ្គលកំពូលមួយរូបរបស់អាស្ហ៍លុល-ស៊ុនណាស់នោះ មានប្រសាសន៍នៅក្នុងសៀវភៅលោក *ឃូនីយ៉ាទុត្ត-ត៏លីប៊ីន (غنيةُ الطَّالِبين)* ថា អាប៊ូ ហ៊ានីហ្វាស់ ត្រូវបណ្តេញចេញពីសាសនា អាស្ហ៍លុល-ស៊ុនណាស់ ។

លោកអ្នកនិពន្ធស៊ុន្នីម្នាក់ឈ្មោះ ម៉េះហ៍ប៊ុប ស៊ុបហានី (Mehboob Subhani) មានប្រសាសន៍ថា យោលតាមហ៊ាឌីស្សព្រះសាស្តា صلى الله عليه وآله وسلم ដែលថា "សហគមន៍ខ្ញុំ صلى الله عليه وآله وسلم នឹងបែកជា ៧៣ និកាយ" នោះ តែការពិត ៧៣ និកាយនោះគឺ ១០ និកាយទេ គឺៈ ១-ស៊ុន្នី, ២-ខ៉ារីយ៉ី (خارجي), ៣-ស៊្ហីអ៊ាស់, ៤-មុតាស៊ីឡាស់ (المعتزلة), ៥-មួរយ៉ីអ៊ាស់ (المرجئة), ៦-មូស្ហាប់ប៊ីហ្វាស់ (مشبهة), ៧-យ៉ាស្ហ៍មីយ៉ាស់ (الجهمية), ៨-ហារូរីយ៉ាស់, ៩-ប៊ូខ៏រីយ៉ាស់, ១០-កាឡាប៊ីយ៉ាស់ ។ បន្ទាប់មកលោកបានសរសេរអំពីសាខារបស់និកាយទាំងនេះ លោកបាននិយាយដល់ ១២ សាខានិកាយមួរយ៉ីអ៊ាស់ ហើយបានឲ្យដឹងថា

សាសនាហ្វាណាហ្ស៊ីជាអនុនិកាយមួយរបស់និកាយមូរយ៉ើអ៊្រស់ មិនរាប់បញ្ចូលនិកាយនេះនៅក្នុងនិកាយស៊ុន្នី (គឺអាស្ហ់លុល-ស៊ុនណាស់) ទេ ។

អស់លោកអ្នកអានបានកត់សម្គាល់ហើយថា យោលតាមសន្តបុគ្គលកំពូលអាស្ហ់លុល-ស៊ុនណាស់ មានតែសាសនាស៊ុន្នីទេដែលសក្តិសមនឹងត្រូវរួចផុតពីនរកនោះ ។ អាស្រ័យហេតុនេះ លោក (គឺសន្តបុគ្គលកំពូលអាស្ហ់លុល-ស៊ុនណាស់) ចាត់ទុក អាប៊ូ ហ្វានីហ្វាស់ និងបណ្តាអ្នកតាមលោកនោះជាបុគ្គលចូលនរក ។ ដោយហេតុថា អាប៊ូ ហ្វានីហ្វាស់ និងពួកអ្នកតាមលោកនោះមិនមានជំនឿដូចបេះបិទនឹងជំនឿរបស់សន្តបុគ្គលកំពូលអាស្ហ់លុល-ស៊ុនណាស់នោះទេ ហើយមានតែអាស្ហ់លុល-ស៊ុនណាស់ទេដែលចាកពីបាបនោះ តើ អាប៊ូ ហ្វានីហ្វាស់ ឬពួកអ្នកតាមលោកណាម្នាក់នោះត្រូវសង្គ្រោះដូចម្តេចទៅ ? យើងត្រូវដឹងថាមានតែសន្តបុគ្គលកំពូលអាស្ហ់លុល-ស៊ុនណាស់ទេដែលមិនបានថា អាប៊ូ ហ្វានីហ្វាស់ ជានិកាយមូរយ៉ើអ៊្រស់នោះ ពួកមេដឹកនាំសាសនាឯទៀតក៏បានរាប់បញ្ចូល អាប៊ូ ហ្វានីហ្វាស់ ក្នុងនិកាយមូរយ៉ើអ៊្រស់ដែរ ។

លោក អ៊ីបនូ គូតៃបាស់ ឌីណាវ៉ារី ក៏បាននិយាយដែរ នៅក្នុងសៀវភៅ *គីតាប អាល់-ម៉ាអ៊្ររិហ្វ (كتاب المعارف)* ថា អាប៊ូ ហ្វានីហ្វាស់ និងគ្រូលោកឈ្មោះ ហ្វាំម៉ាដ់ ប៊ិន អាប៊ូ ស៊ូឡៃម៉ាន និងសិស្សលោកពីរនាក់ឈ្មោះ ក៏ឌី អាប៊ូ យូស៊ុហ្វ និង មូហ្វាំម៉ាដ់ ប៊ិន ហ្វាសាន់ ជានិកាយមូរយ៉ើអ៊្រស់ ។ ម្យ៉ាងទៀត សិស្សរបស់លោកតែម្តងគឺ អ៊ីម៉ាំ អាប៊ូ យូស៊ុហ្វ ក៏ហាក់ដូចជាជឿជាក់ថាលោកជានិកាយមូរយ៉ើអ៊្រស់ដែរ ។ គ្រាមួយ ក៏ឌី អាប៊ូ យូស៊ុហ្វ បាននិយាយដល់ អាប៊ូ ហ្វានីហ្វាស់ ដែរថាលោកជានិកាយយ៉ាស្ហ់មីយ៉ាស់ ថែមទាំងបានចោទលោកថាជាខ្ស៊ីរយ៉ើ[5]ទៀតផង ! សម្តីរបស់អ៊ីម៉ាំ អាប៊ូ យូស៊ុហ្វ នេះមានចារទុកនៅក្នុងក្រាំង *តារិក្ក អាល់-បាក់ដ្ហាដ់ (تاريخ بغداد)* ។

ពុំមានអ្វីគួរឲ្យសង្ស័យទេ អ្នកនិពន្ធភ្ញាក់ផ្អើលខ្លាំងណាស់អំពីរឿងទាំងអស់នេះក្នុងពេលស្រាវជ្រាវ គួរឲ្យភ្ញាក់ផ្អើលលើសពីនេះគឺ បណ្តាអ្នកកាន់សាសនាហ្វាណាហ្ស៊ីសព្វថ្ងៃនេះតែម្តងដែលមិនអាចបោះបង់ចោលសន្តបុគ្គលកំពូលអាស្ហ់លុល-ស៊ុនណាស់ ហើយក៏មិនអាចដកខ្លួនចេញពី អាប៊ូ ហ្វានីហ្វាស់ ! ខ្ញុំអាណិតបណ្តាអ្នកដែលសូត្រធម៌ឧទ្ទិសក្នុងថ្ងៃទី ១១ ខែ រ៉ប់ប៊ីអ៊្រស្ស៊្រ-ស្ហ្ហានី (ថ្ងៃបុណ្យខួបលោក អ៊្រប់ឌុល ក៏ដ្ឌៀរ យ៉ើឡានី ទទួលអនិច្ចកម្ម) តែទោះជាយ៉ាងនេះក្តី យោលតាមសម្តីរបស់សន្តបុគ្គលកំពូលអាស្ហ់លុល-ស៊ុនណាស់នោះ ពួកគាត់ទាំងអស់គ្នាត្រូវបណ្តេញចេញពីក្រុមអាស្ហ់លុល-ស៊ុនណាស់ ហើយពុំមានសិទ្ធិចូលឋានសួគ៌ទេ ។ អ្នកនិពន្ធអស់អែកណាស់ក្នុងអំឡុងពេលធ្វើការស្រាវជ្រាវនោះ តែអល់ឡោះហ្ហ៍عزّ وجلّនឹងរំដោះទុក្ខនៅពេលខាងមុខ ។

[5] ពួកប្រឆាំងអ៊ីម៉ាំ អ៊្រលី صلوات الله عليه والسلام ។